**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

លេខ: ៩៩៧៩ អឯក.អគ.មអជ

ថ្ងៃ សុក្រ ០៦ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ៦ ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា៖ គោលនយោបាយវិស័យថាមពលរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៦ នៃរដ្ឋសភានេះ **រាជរដ្ឋាភិបាលកម្ពុជា** មានមហិច្ឆតាគ្រប់គ្រងនិងជំរុញការអភិវឌ្ឍវិស័យថាមពលអគ្គិសនីដើម្បី "ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែង ទូទាំងព្រះរាជាណាចក្រកម្ពុជា"។ **អគ្គិសនីកម្ពុជា** បន្តផ្តល់ថវិកាជាអំណោយដល់នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (ហៅកាត់ថា "ម.អ.ជ.") ដើម្បីបន្តអនុវត្ត **"កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ មានប័ណ្ណសមធម៌"**។ កម្មវិធីនេះ ជាកម្មវិធីអនុវត្តពីឆ្នាំ២០១៧ និងបន្តអនុវត្តក្នុងឆ្នាំ២០២១។ គោលបំណងនៃកម្មវិធីគឺជួយដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌នៅតំបន់ជនបទ អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនី ពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ថវិកាឧបត្ថម្ភធនចំនួន ១០០ដុល្លារអាមេរិក ក្នុង១គ្រួសារ តាមរយៈអ្នកកាន់អាជ្ញាបណ្ណសម្រាប់៖ ១-ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន និង ២- ចំណាយលើការរៀបចំខ្សែបណ្តាញនិងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 015 776-770 / 011 244-246 ឬលោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 089 776-770 / 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅ ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

<u>ចម្លងជូន៖</u>

- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ